MEKONG RIVER COMMISSION MRC FOR SUSTAINABLE DEVELOPMENT

# សហគមន៍មានសុវត្ថិភាព ២

adpc

មិថុនា ២០០៩

# ពង្រឹងការផ្សព្វផ្សាយព័ត៌មានព្យាករណ៍កំពស់ទឹកទឹកជំនន់ តាមរយៈប្រព័ន្ធផ្តល់ព័ត៌មានជាមុនពីគ្រោះទឹកជំនន់ នៅមូលដ្ឋានសហគមន៍

## ការកសាងសមត្ថភាពសហគមន៍ងាយរងគ្រោះដោយសារគ្រោះទឹកជំនន់នៅក្នុងប្រទេសកម្ពុជា

### ព័ត៌មានសង្ខេប

ករណីសិក្សានេះ បានបង្ហាញពីលក្ខណៈនៃ ប្រព័ន្ធផ្តល់ពត៏មានជាមុនពីគ្រោះទឹកជំនន់ដែលមាននៅតាមស្រុកទាំង៤ក្នុងប្រទេសកម្ពុជា។ ដោយពិនិត្យមើលលើប្រព័ន្ធផ្តល់ពត៏មានជាមុន នៅថ្នាក់ជាតិ ខេត្ត ស្រុក ដែលមានស្រាប់ពីមុនៗមក ករណីសិក្សានេះ បានលើកឡើង ពីគំនិតសំខាន់ៗ និងសកម្មភាពដែលបានរួមចំនែកក្នុងការធ្វើអោយមាននិរន្តរភាពនៃប្រព័ន្ធផ្តល់ពត៏មានជាមុនពីគ្រោះទឹកជំនន់នៅ ខេត្តព្រៃវែង និង ខេត្តកណ្តាល។ ប្រព័ន្ធនេះមានទំនាក់ទំនងជាមួយកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និង ស្រុក ដែលជាចំនែកដ៏សំខាន់មួយក្នុងការធ្វើអោយមាននិរន្តរភាពលើប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ និងជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍មូលដ្ឋាន។

### ខ្លឹមសាររឿង

■ ប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ដែលមានស្រាប់នៅកម្ពុជា ២
■ ការពង្រឹងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់នៅថ្នាក់សហគមន៍ ៤
■ បទពិសោធន៍ មេរៀនទទួលបាន និងឧបសគ្គនៅពេលអនាគត ៧




*ជារៀងរាល់ឆ្នាំនៅក្នុងអាងទន្លេមេគង្គ ទឹកទន្លេមេគង្គបានហូរ និងជន់លិចច្រាំងទន្លេ និងបានបណ្តាលឱ្យមានការខូចខាតដោយមិនដឹងជាមុនដល់ភូមិនៅជុំវិញអាងទន្លេនេះ ។ ការធ្វើការដោយផ្ទាល់ជាមួយនឹងសហគមន៍មូលដ្ឋាន ជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការកាត់បន្ថយផលប៉ះពាល់នៃគ្រោះទឹកជំនន់ ។ ហេតុដូច្នេះ ហើយបានជាប្រទេសកម្ពុជា បាននឹងកំពុងអនុវត្តគំរោងប្រព័ន្ធផ្តល់ពត៏មានជាមុនពីទឹកជំនន់នៅមូលដ្ឋានសហគមន៍ ក្នុងគោលបំណងកសាងសមត្ថភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតាមមូលដ្ឋាន ដើម្បីអោយគេអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ទៅនឹងគ្រោះមហន្តរាយទឹកជំនន់ និងធានានិរន្តរភាពនៅពេលអនាគត ។គំនិតផ្តួចផ្តើមនេះជាការចាប់ផ្តើមមួយសំរាប់ធ្វើអោយអ្នកភូមិនិងសហគមន៍អាចធ្វើការសំរេចចិត្តក្នុងការចាត់វិធានការការពារដ៏សមស្រប ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃគ្រោះទឹកជំនន់ ។*

### សេចក្តីផ្តើម

ដោយមានការប្រែប្រួលធាតុអាកាស, ការបាត់បង់ព្រៃឈើ និងសកម្មភាពអភិវឌ្ឍន៏ដែលខ្វះផែនការច្បាស់លាស់ជាហេតុធ្វើអោយមានកាខូចខាតដោយគ្រោះទឹកជំនន់ប្រចាំឆ្នាំនៅតាមដីសណ្តទន្លេមេគង្គ។ អាយុជីវិតបានបាត់បង់, ផលដំណាំត្រូវបំផ្លិចបំផ្លាញហើយជីវភាពរស់នៅតែងតែរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ មានសារៈសំខាន់នៅក្នុងតំបន់នេះ ព្រោះប្រព័ន្ធនេះបានជួយកាត់បន្ថយការបំផ្លាញ ដោយបានផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ដល់សហគមន៏ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងទឹកជំនន់អំពីភាពងាយរង

គ្រោះ និងការគំរាមគំហែងអាក្រក់ណាមួយនៃមហន្តរាយទឹកជំនន់ ។

តើប្រព័ន្ធផ្តល់ពតិមានជាមុននេះ បានអនុវត្តយ៉ាងដូចម្តេច? នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ បានចាប់ផ្តើមដោយបានសហការជាមួយនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ(DHRW) ។នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេបានបង្កើតប្រព័ន្ធព្យាករណ៍ទឹកជំនន់និងធ្វើការផ្សព្វផ្សាយដល់ក្រសួងពាក់ព័ន្ធ, មន្ទីរ-អង្គភាព តាមស្រុកនិងបណ្តាញពតិមាននានាដូចជាស្ថានីយ៍វិទ្យុជាតិក៏បានផ្សព្វផ្សាយពតិមានសំខាន់នេះជាសាធារណៈផងដែរ ។

ដើម្បីអោយប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់បែបនេះកាន់តែមានប្រសិទ្ធភាពឡើង សហគមន៍ ត្រូវតែប្រើប្រាស់ធនធានដែលមាន ដើម្បីធ្វើការឆ្លើយតបទឹងប្រព័ន្ធផ្តល់ពតិមានជាមុននេះ ឱ្យមានប្រសិទ្ធភាព ។ គណៈកម្មការទន្លេមេគង្គ(MRC)បានសហការជាមួយ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ដើម្បីអនុវត្តកម្មវិធីប្រព័ន្ធផ្តល់ពត៌មានជាមុននៅមូលដ្ឋានសហគមន៍ ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតាមមូលដ្ឋាន និងដើម្បីធានាប្រសិទ្ធភាពក្នុងការត្រៀមបង្ការគ្រោះទឹកជំនន់ ។ សកម្មភាពនេះគឺជាផ្នែកមួយនៃការអនុវត្ត ផ្នែកទី៤ " គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ " នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់របស់គណៈកម្មការទន្លេមេគង្គ ។

នៅក្នុងប្រទេសកម្ពុជាសហគមន៍ជាច្រើនបានពឹងផ្អែកលើជំនួយពីរាជរដ្ឋាភិបាល នៅពេលមានទឹកជំនន់ ។ ឯកឧត្តម ប៉ុន ណារិទ្ធ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) បានមានប្រសាសន៍ថា "កាលពីមុនរាជរដ្ឋាភិបាលបានធ្វើការឆ្លើយតបទឹងភាពអាសន្ន និងផ្តល់ជំនួយសង្គ្រោះ ចំណែកឯប្រជាជនរង់ចាំតែទទួលស្បៀងអាហារ និងសំភារៈ" ។

បើសិនសហគមន៍មានសមត្ថភាពការពារអាយុជីវិតនិងទ្រព្យសម្បត្តិរបស់ពួកគេខ្លួនឯងនោះ គេនឹងមានការពឹងផ្អែកតិចតួចតែប៉ុណ្ណោះពីជំនួយខាងក្រៅ ។ និរន្តរភាពគឺត្រូវបានបង្កើតនៅពេលដែល សហគមន៍មូលដ្ឋានបានចូលរួមនៅក្នុងការត្រៀមបង្ការ ដោយប្រើប្រាស់ធនធានដែលមានជាក់ស្តែងរបស់គេបាន ។ ការទទួលខុសត្រូវរបស់សហគមន៍ ដែលជាអ្នកទទួលរងការប៉ះពាល់ដោយផ្ទាល់ដោយ គ្រោះទឹកជំនន់ អាចដោះស្រាយបានដោយមានប្រសិទ្ធិភាពនិងទាន់ពេលវេលា ។ធ្វើដូច្នេះ វានឹងបង្កើតអោយមានស្មារតីម្ចាស់ការលើខ្លួនឯង ។

## ប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់ជាមុនដែលមានស្រាប់ នៅក្នុងប្រទេសកម្ពុជា ~ ការកសាងមូលដ្ឋានគ្រឹះ

ប្រទេសកម្ពុជាធ្លាប់មានប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ជាយូរមកហើយ ។ សហគមន៍នៅមូលដ្ឋានត្រូវការពតិមានព្យាករណ៍ពីកំពស់ទឹកជំនន់ពីស្ថាប័នជាតិដើម្បីគេអាចមានវិធានការត្រៀមបង្ការអោយបានយ៉ាងត្រឹមត្រូវ ។ ជាមួយគ្នានេះដែរ រចនាសម្ព័ន្ធរាជរដ្ឋាភិបាលត្រូវការពតិមានពីសហគមន៍ ដើម្បីយល់ដឹងបានទូវធនធាន ដែលត្រូវការសំរាប់ប្រើប្រាស់នៅពេលមានទឹកជំនន់ ។ មានគំរោងផ្តល់ពតិមានជាមុនពីទឹកជំនន់ជាច្រើនដែលបាននិងកំពុងអនុវត្តន៍នៅក្នុងប្រទេសកម្ពុជាចាប់តាំងពី ឆ្នាំ ២០០៣ មកដែលប្រព័ន្ធនិមួយៗ មានចំនុចខ្លាំង បទពិសោធន៍ និងមេរៀនដែលរៀនបានជាច្រើន ។

ប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ដែលមានប្រសិទ្ធភាពជាប្រព័ន្ធដែលមានលក្ខណៈសាមញ្ញ ងាយយល់ ។ គោលបំណងនៃប្រព័ន្ធនេះ ដើម្បីកំនត់ពីភាពដែលអាចកើតឡើង រៀបចំពតិមានផ្សព្វផ្សាយជាមុន និងដើម្បីរៀបចំធ្វើអោយមានការឆ្លើយតបរបស់សហគមន៍ ។ គំរោងនិមួយៗខាងក្រោមនេះមានផ្នែកផ្សេងៗប្រហាក់ប្រហែលគ្នា ។

### ការផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់

គំរោងរបស់គណៈកម្មការទន្លេមេគង្គដែលមានឈ្មោះថា " ការផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ទៅកាន់សហគមន៍ដែលងាយរងគ្រោះដោយសារទឹកជំនន់នៅតាមអាងទន្លេមេគង្គក្រោម " ដែលឧបត្ថម្ភថវិកាពីការិយាល័យជំនួយសង្គ្រោះបរទេសរបស់សហរដ្ឋអាមេរិក (OFDA) ដែលបានអនុវត្តគំរោងផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់នៅតាមសហគមន៍ជាលើកដំបូងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០០៣ ដល់ ឆ្នាំ ២០០៧ ដោយបានសហការជាមួយកាកបាទក្រហមអាមេរិកកាំង (ARC) និងកាកបាទក្រហមកម្ពុជា (CRC) ។

គំរោងនេះបានគ្របដណ្តប់សហគមន៍គោលដៅងាយរងគ្រោះ បានចំនួនដល់ទៅ ៤០ភូមិ តាមបណ្តោយដងទន្លេមេគង្គ និង ដៃរបស់វានៅក្នុងខេត្តគោលដៅចំនួន៥ ក្នុងនោះរួមមាន ខេត្តស្ទឹងត្រែង កំពង់ចាម ក្រចេះ កណ្តាល និង ព្រៃវែង ។

ប្រព័ន្ធផ្តល់ពតិមានបែបនេះបានរៀបចំប្រព័ន្ធផ្សព្វផ្សាយពតិមានព្យាករណ៍ពីកំពស់ទឹកស្តង់ដាមួយ ដែលមានសារៈសំខាន់ និងងាយយល់បាន





ដែលទទួលពត៌មាននេះពីតាមភូមិក្នុងតំបន់លិចទឹកជំនន់។ សហគមន៍នៅតាមតំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់អាចឆ្លើយតបបានយ៉ាងល្អទៅនឹងពត៌មានព្យាករណ៍ដែលផលិតដោយនាយកដ្ឋានជលសាស្រ្តនិងការងារទន្លេ(DHRW)ដោយបានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ (MRC)។ ប្រព័ន្ធផ្តល់ពត៌មានជាមុននៅតាមសហគមន៍ ដែលបង្កើតឡើងនៅតាមភូមិគោលដៅនីមួយៗ មានដូចជាបង្គោលម៉ែត្រស្ទង់ទឹក, ក្តារខៀនពត៌មានកំពស់ទឹក (ជាកន្លែងដែលពត៌មានព្យាករណ៍កំពស់ទឹកតាមភូមិរាល់ថ្ងៃត្រូវបានបង្ហាញជារៀងរាល់ថ្ងៃ), វិទ្យុទាក់ទងឬអាយកូម និង មេគ្រូ ជាដើម។

ផែនទីភូមិដែលគូរដោយដៃដែលមានលក្ខណៈងាយយល់ ត្រូវបានរៀបចំដោយមានបង្ហាញពីផ្លូវគមនាគមន៍ និងទីតាំងទីទួលសុវត្ថិភាពជាដើម ។

លើក្តារខៀនពត៌មានកំពស់ទឹក មានបង្ហាញពីសញ្ញាកំរិតប្រកាសអោយដឹងជាមុនដោយមានប្រើប្រាស់ពណ៌ផ្សេងៗគ្នា ដូចជាពណ៌ក្រហម "ប្រាប់ស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលធ្ងន់ធ្ងរ " ពណ៌លឿង "ប្រាប់ពីស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលប្រកាសអាសន្ន" និងពណ៌ខៀវ បង្ហាញពី "ទឹកជំនន់មានស្ថានភាពធម្មតា" និងមានកំរិតទឹកជំនន់ប្រចាំថ្ងៃពីស្ថានីយ៍ និងពីបង្គោលម៉ែត្រតាមភូមិផងដែរ។

អ្នកស្ម័គ្រចិត្តកាកបាទក្រហម(RCVs)មានភារកិច្ចថែទាំក្តារពត៌មានហើយធ្វើការជាមួយសហគមន៍មូលដ្ឋានក្នុងការផ្សព្វផ្សាយពត៌មានទឹកជំនន់ដ៏សំខាន់នេះដល់សហគមន៍រៀងរាល់ថ្ងៃ ។

## មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍

មានមេរៀនបទពិសោធន៏ជាច្រើនដែលទទួលបានពីគំរោងតំបូងនេះ។អ្នកភូមិមានកំរិតចំនេះដឹងទាបដែលធ្វើអោយមានឧបសគ្គទៅ ដល់ដំណើរការផ្សព្វផ្សាយពត៌មានកំពស់ទឹកជំនន់នៅក្នុងសហគមន៍។ ដូច្នេះត្រូវគិតគូរពីវិធីសាស្រ្តក្នុងការទំនាក់ទំនងជាមួយអ្នកភូមិដែលមានចំនេះដឹងទាប ។

ការផ្សាយពត៌មាន ក៏ជាឧបសគ្គមួយទៀតដោយការខ្វះហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៏ជនបទ។ ចំពោះអ្នកដែលរស់នៅក្បែរ ក្តារខៀនពត៌មានអាចទទួលបានពត៌មានការព្យាករណ៍ទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ ការផ្សព្វផ្សាយពត៌មាននេះទៅដល់សហគមន៍ដាច់ស្រយាលមានការរអាក់រអួលដោយសារខ្វះផ្លូវធ្វើដំណើរ និងមធ្យោបាយធ្វើដំណើរ ឧ. ទូក ជាដើម ។ អ្នកស្ម័គ្រចិត្តកាកបាទក្រហម (RCVs) តែងចុះទៅពិនិត្យមើលតាមផ្ទះ ដែលនៅក្នុងភូមិដាច់ស្រយាល ដោយសារគេមិនអាចមកមើលពត៌មានលើក្តារពត៌មានដែលបានតំលើងនោះបាន។ មេគ្រូបានប្រើដើម្បីផ្សព្វផ្សាយពត៌មានកំពស់ទឹក។ លើសពីនេះ វិទ្យុទាក់ទងឬអាយកូមតែងតែដាច់ ប៉ុស្តិ៍ ឬ គ្មានសេវាពេលមានខ្យល់ និង ភ្លៀងខ្លាំង ។

ខណៈដែល គំរោងផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ (EWS) បានធ្វើការដើម្បីពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្នុងការរៀបចំប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយពត៌មានព្យាករណ៍ទឹកជំនន់ដែលមានប្រសិទ្ធភាព ដូច្នេះក្នុងជំហានបន្តបន្ទាប់នៃគំរោងនេះ មានបំណងធ្វើការ យ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបន្តពង្រឹងសមត្ថភាពដល់ថ្នាក់ឃុំទៀត។ ការប្រើប្រាស់អ្នកស្ម័គ្រចិត្តកាកបាទក្រហម ដើម្បីអនុវត្តគំរោងនេះ មិនសូវមាននិរន្តរភាពរឹងមាំទេ ដោយសារគេអាចធ្វើការបានយ៉ាងល្អនៅពេលដែល មានគំរោងពីបណ្តាអង្គភាពដៃគូនានា តែនៅពេលគំរោងនេះដកចេញ បណ្តាញនេះមិនសូវមានភាពសកម្មក្នុងការអនុវត្តការងារនេះទេ ។

## គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់របស់អង្គការប្រឆាំងគ្រោះអត់ឃ្លាន (ACF)

ដោយបានការឧបត្ថម្ភថវិកាពីការិយាល័យត្រៀមបង្ការគ្រោះមហន្តរាយរបស់ជំនួយមនុស្សធម៌សហគមន៍អ៊ឺរ៉ុប (DIPECHO) គណៈកម្មការទន្លេមេគង្គ (MRC) បានសហការជាមួយនឹងអង្គការប្រឆាំងគ្រោះអត់ឃ្លាន ក្នុងសកម្មភាពដូចគ្នានឹងគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់របស់កាកបាទក្រហមកម្ពុជា និងកាកបាទក្រហមអាមេរិកកាំងខាងលើ។ គំរោងនេះបានអនុវត្តនៅក្នុងភូមិគោលដៅចំនួន ៩ ក្នុងខេត្តកំពង់ចាម។ គំរោងនេះមិនផ្តោតសំខាន់តែទៅលើប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ប៉ុណ្ណោះទេ តែគំរោងនេះបានអនុវត្តដោយផ្ទាល់ជាមួយក្រុមគ្រប់គ្រងគ្រោះមហន្តរាយ លើការងោរត្រៀមបង្ការគ្រោះទឹកជំនន់ផងដែរ។ គំរោងរបស់អង្គការ ACF ទាក់ទងនឹងប្រព័ន្ធផ្តល់ពត៌មានជាមុន មានលក្ខណៈខុសគ្នាពីគំរោងរបស់កាកបាទក្រហមកម្ពុជា និងកាកបាទក្រហមអាមេរិកកាំងត្រង់ថា គំរោងនេះធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរខេត្ត ស្រុក ព្រមទាំងជាមួយRCV និង អ្នកដឹកនាំសហគមន៍ ក្នុងការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់។ ការចូលរួមរបស់មូលដ្ឋាននៅក្នុង

គំរោងនេះបានជួយបង្កើតនូវមូលដ្ឋានគ្រឹះ នៅក្នុងភាពជាម្ចាស់ការ និង និរន្តរភាពរបស់សហគមន៍យូរអង្វែង ។

ដោយការប្រើប្រាស់ប្រព័ន្ធដូចគ្នានឹងប្រព័ន្ធក្រោមគំរោងរបស់ ARC និង CRC, គំរោងរបស់អង្គការ ACF នេះមានការផ្តល់ពត៌មានជាមុនដល់អ្នកភូមិតាមរយៈការប្រើប្រាស់ក្តារពត៌មាន បង្គោលម៉ែត្រស្ទង់ទឹក និងមេក្រូសំរាប់ការផ្សាយពត៌មានពីភាពអាសន្ន និងមានការកិច្ចសហការដោយផ្ទាល់ជាមួយនឹងមន្ទីរពត៌មាន ខេត្តកំពង់ចាមដើម្បីជួយផ្សព្វផ្សាយពត៌មានតាមប្រព័ន្ធផ្សព្វផ្សាយវិទ្យុធំ នេះជាវិធីសាស្ត្រមានប្រសិទ្ធភាពមួយ សំរាប់ការផ្សាយពត៌មានដល់ប្រជាជន ។

អ្នកភូមិមួយចំនួនបានបង្កើតបង្គោលម៉ែត្រស្ទង់ទឹកដោយខ្លួនគេ នៅតាមផ្ទះ។ គេធ្វើដូចនេះ មានភាពងាយស្រួល ដោយមិនចាំបាច់ធ្វើ ដំណើរទៅមើលកំរិតកំពស់ទឹកនៅកន្លែងណាដែលមានបង្គោល ។ ទាំងនេះជាផលប្រយោជន៍ ដែលបង្គោលម៉ែត្រស្ទង់ទឹកនេះបានត្រូវធ្វើបន្តគ្នានៅតំបន់ដាច់ស្រយាលជាច្រើន។

### មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍

គំរោង ACF នេះក៏បានជួបប្រទះនូវផលលំបាកជាច្រើនដែរ ដូចជាកំរិតនៃការយល់ដឹងរបស់សហគមន៍មូលដ្ឋានមានកំរិតទាប ឧទាហរណ៍មានការកត់ត្រាកំពស់ទឹកមិនបានត្រឹមត្រូវពីបង្គោលម៉ែត្រស្ទង់ទឹក ដែលជាហេតុធ្វើអោយការរៀបចំពត៌មានសំរាប់ ព្យាករណ៍ មិនត្រឹមត្រូវ និង ធ្វើអោយមានបាត់ទំនុកចិត្តរបស់អ្នកភូមិ លើគំរោងប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់នេះ។

### គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់ របស់អង្គការអុកស្វាម អង់គ្លេស (Oxfam-GB)

ប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់ជាមុននេះឧបត្ថម្ភដោយអង្គការ អុកស្វាមអង់គ្លេស (Oxfam-GB) ចាប់ពីឆ្នាំ ២០០៣ ដល់ ២០០៥។គំរោងនេះបានអនុវត្តនៅក្នុង១៣ភូមិនៅក្នុងស្រុកចំនួន៣របស់ខេត្តតាកែវ ។គំរោងនេះផងដែរបានយកតាមរបៀបនៃគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនរបស់គណៈកម្មការទន្លេមេគង្គ MRC ដូចជាមានដាក់បង្គោលម៉ែត្រស្ទង់ទឹក និង ក្តារខៀនពត៌មានជាដើម។ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពត៌មានព្យាករណ៍ដល់សហគមន៍ពីការត្រៀមបង្ការនឹងទឹកជំនន់។

### មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍

ការផ្សព្វផ្សាយពត៌មានដល់ភូមិដែលនៅឆ្ងាយពីកន្លែងដាក់ បង្គោលម៉ែត្រស្ទង់ទឹកជាបញ្ហាលំបាក និង ត្រូវយកចិត្តទុកដាក់។

## ការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅថ្នាក់សហគមន៍ នៅក្រោមគំរោងពង្រឹង ការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់មានសារៈ សំខាន់នៅក្នុងការកាត់បន្ថយគ្រោះមហន្តរាយទឹកជំនន់នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយបានជាមានការបន្តរបៀបត្រៀមបង្ការគ្រោះទឹកជំនន់ ដោយប្រើប្រាស់ប្រព័ន្ធប្រភេទនេះនៅថ្នាក់ឃុំ។ការកសាងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋានជាវិធីសាស្ត្រសមស្របដែលអាចជួយបង្កើននូវភាពម្ចាស់ការ និងជំនឿទុកចិត្ត ដូច្នេះវាឈានទៅរកនិរន្តរភាពនៃការត្រៀមបង្ការគ្រោះមហន្តរាយយូរអង្វែង។ ជាមួយគ្នានេះដែរ វាអាចជួយធ្វើអោយមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនៃការផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់។

គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ឧបត្ថម្ភថវិកាពីភ្នាក់ងារសហប្រតិបត្តិការផ្តល់ជំនួយបច្ចេកទេសអន្តរជាតិប្រទេស អាឡឺម៉ង់ (GTZ) ដើម្បីពង្រឹងការយល់ដឹងពីប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅថ្នាក់មូលដ្ឋាន ដោយផ្អែកលើបទពិសោធន៍ និង មេរៀនទទួលបានពីគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់មុនៗ ។ ដូច្នេះហើយ បានជាចាប់តាំងពីឆ្នាំ ២០០៤ មកគំរោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ ផ្នែកទី ៤ នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់បានកំនត់យកប្រព័ន្ធផ្តល់ពត៌មានជាមុន ពីទឹកជំនន់នៅមូលដ្ឋានសហគមន៍ (CBEWS) ជាសកម្មភាពអាទិភាពមួយដែលត្រូវអនុវត្ត ដូចដែលបានកំនត់ នៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ (FPP)។ ប្រព័ន្ធនេះគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុកជាអ្នកគ្រប់គ្រងនិងដឹកនាំអនុវត្ត ។

រចនាសម្ព័ន្ធ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM)




រចនាសម្ព័ន្ធ និង តួនាទីសំខាន់របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គឺដើម្បីអនុវត្តនយោបាយថ្នាក់ជាតិស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ( *សូមមើលប្រអប់រចនាសម្ព័ន្ធរបស់ PCDM* )។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត មានភារកិច្ចរៀបចំសេចក្តីណែនាំ និងគាំទ្រសកម្មភាពរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ។គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តជាអ្នករាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM)នូវរាល់សកម្មភាពដែលអនុវត្ត ដោយអាជ្ញាធរខេត្ត និងអង្គការក្រៅរដ្ឋាភិបាលនានានៅថ្នាក់ខេត្ត។នៅថ្នាក់

ខេត្ត និងស្រុក អភិបាលខេត្តរង និង អភិបាលស្រុករងជាប្រធានក្រុមប្រតិបត្តិការនៃក្រុមទាំង៤គឺក្រុមរុករក សង្គ្រោះ និង សន្តិសុខ, ក្រុមសុខភាព អនាម័យ និងទឹកអនាម័យ, ក្រុមគ្រប់គ្រងពត៌មាននិងប៉ាន់ប្រមាណនិងក្រុមប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារជួសជុលឡើងវិញ ។ លើសពីនេះទៀត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តជាអ្នកធ្វើសេចក្តីរាយការណ៍ពីការខូចខាត និង ខូចខាតដោយគ្រោះមហន្តរាយ ហើយរៀបចំសំណើរសុំជំនួយហិរញ្ញវត្ថុ និង សំភារៈ និងការអន្តរាគមន៍ នៅពេលមានគ្រោះមហន្តរាយកើតឡើង។

## គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់ នៅមូលដ្ឋានសហគមន៍

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅមូលដ្ឋានសហគមន៍ជាកម្មវិធីពង្រឹងសមត្ថភាព និង ជំនាញគ្រប់គ្រងគ្រោះមហន្តរាយ។ គោលដៅកម្មវិធីនេះ គឺដើម្បីបង្កើនការយល់ដឹងជា សាធារណៈនៅក្នុងសហគមន៍ និងធានានូវនិរន្តរភាពនៃប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់ជាមុននៅថ្នាក់សហគមន៍។ តំបន់គោលដៅនៃ កម្មវិធីនេះ គឺស្រុកពាមជរ ខេត្តព្រៃវែង ដែលមាន ៩ភូមិគោលដៅ។

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅមូលដ្ឋានសហគមន៍បានចូលរួមចំណែកយ៉ាងច្រើនក្នុងការពង្រឹងសមត្ថភាពថ្នាក់ជាតិក្នុងការត្រៀមបង្ការគ្រោះទឹកជំនន់។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិអាចប្រើប្រាស់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់គំរូនេះ ដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋាននៅក្នុងការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ដោយផ្តោតសំខាន់លើតំបន់ណាដែលត្រូវការ។

គោលបំណងនៃគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅមូលដ្ឋានសហគមន៍មានពីរយ៉ាង ៖ ប្រើប្រាស់បង្គោលម៉ែត្រស្ទង់ទឹក ជាឧបករណ៍សំរាប់គ្រប់គ្រងគ្រោះទឹកជំនន់នៅក្នុងសហគមន៍ងាយរងគ្រោះ និងដើម្បីកាត់បន្ថយផលប៉ះពាល់ទឹកជំនន់តាមរយៈការបង្កើនសមត្ថភាពជួយខ្លួនឯង នៅក្នុងការគ្រប់គ្រងគ្រោះទឹកជំនន់ ទាំងនៅមុនពេល កំឡុងពេល និងក្រោយពេលនៃទឹកជំនន់។

សកម្មភាពនៅក្នុងគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ នេះត្រូវអនុវត្តជា២ដំណាក់កាល គឺមុនពេល និងកំឡុងពេល ។ នៅមុនពេលទឹកជំនន់មានការប្រជុំមួយជាមួយ នឹងមេឃុំ និងមេភូមិ អ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកភូមិ ដើម្បីកំនត់តំបន់គោលដៅ ភូមិចំនួន ៩ នៅតាមបណ្តោយ ដងទន្លេតូច ត្រូវបានកំនត់យកជាភូមិគោលដៅក្នុងខេត្តព្រៃវែងក្នុងប្រទេសកម្ពុជា។ បង្គោលម៉ែត្រស្ទង់ទឹក និង ក្តារខៀនពត៌មានកំពស់ទឹក ត្រូវដាក់នៅតាមភូមិនិមួយៗ ហើយឧបករណ៍ទំនាក់ទំនងត្រូវផ្តល់ដល់ថ្នាក់ខេត្ត ស្រុក ឃុំ និង ថ្នាក់ភូមិ ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM) និងអាជ្ញាធរភូមិបានទទួលវគ្គបណ្តុះបណ្តាលពីនាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ ពីការអនុវត្តន៍ និងការថែរក្សាបង្គោលម៉ែត្រស្ទង់ទឹក និងក្តារខៀនពត៌មានកំពស់ទឹក ការប្រមូលទិន្នន័យកំពស់ទឹកជំនន់បង្គោលម៉ែត្រស្ទង់ទឹកអោយបានត្រឹមត្រូវ និង ផ្សព្វផ្សាយពត៌មាន កំពស់ទឹកលើក្តារពត៌មាន ។

ដោយមានការគាំទ្រពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេដើម្បីធ្វើការព្យាករណ៍កំពស់ទឹកជំនន់អោយបានត្រឹមត្រូវ វាអាស្រ័យលើការប្រមូលពត៌មានប្រចាំថ្ងៃពីស្ថានីយ៍នៅតាមបណ្តោយដងទន្លេមេគង្គ។ នៅរដូវទឹកជំនន់ តាមភូមិនិមួយៗបានកត់ត្រាកំពស់ទឹកជំនន់នៅតាមភូមិរបស់គេជារៀងរាល់ថ្ងៃហើយបានរាយការណ៍ពត៌មានដែលគេប្រមូលបានដោយប្រើប្រាស់វិទ្យុទាក់ទង ឬ អាយកូមដល់អាជ្ញាធរស្រុក។ បន្ទាប់មក កំរិតកំពស់ទឹក ត្រូវបញ្ជូនទៅអោយនាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេតាមរយៈប្រព័ន្ធទំនាក់ទំនងដែលមានស្រាប់ *(សូមមើលលំហូរពត៌មានក្នុងប្រអប់)*។

យកដ្ឋានជលសាស្ត្រ និង ការងារទន្លេ (DHRW) បានបញ្ជូនពត៌មានព្យាករណ៍ដល់ភូមិវិញតាមប្រព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក (PCDM/DCDM) តាមរយៈមន្ទីរធនធានទឹកខេត្ត។ ពត៌មានកំពស់ទឹកជំនន់ ដែលកត់ត្រាដោយមេភូមិ ត្រូវបានផ្សព្វផ្សាយលើក្តារខៀនពត៌មានដែលដាក់នៅតាមភូមិ។ ពត៌មានព្យាករណ៍ដែលបានផ្សព្វផ្សាយលើក្តារខៀនពត៌មានមានរយៈពេល៣ថ្ងៃ គឺនៅថ្ងៃនេះ ថ្ងៃស្អែក និង ខានស្អែក ដោយប្រើប្រាស់ សញ្ញាព្រួញ ចង្អុលឡើង (កំរិតទឹកឡើង) និងសញ្ញាព្រួញចង្អុលចុះ (កំរិតទឹកថយចុះ)។ មានសញ្ញាប្រកាសភាពអាសន្នផ្សេងទៀតដែលមានពណ៌ផ្សេងៗគ្នា អាស្រ័យលើកំពស់ទឹកជាក់ស្តែង ដូចជា ពណ៌ ក្រហម ប្រាប់ស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលធ្ងន់ធ្ងរ ពណ៌លឿង ប្រាប់ពីស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលប្រកាសអាសន្ន និងពណ៌ខៀវគឺទឹកជំនន់មានស្ថានភាពធម្មតា។ នៅក្នុងរូបភាពក៏បង្ហាញពីសញ្ញាព្រួញដែលមានពណ៌ខុសគ្នាសំរាប់ផ្តល់ពត៌មានដល់សហគមន៍ ដើម្បីអោយគេចាត់វិធានការត្រៀមបង្ការអោយបានទាន់ពេលវេលា។

សមាជិកសហគមន៍ ក៏បានបណ្តុះបណ្តាលក្នុងការឆ្លើយតបទៅ នឹងការផ្តល់ពត៌មានជាមុនស្តីពីទឹកជំនន់តាមរយៈការយុទ្ធនាផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈការបង្កើនការយល់ដឹងពីវិធានការត្រៀមបង្ការគ្រោះទឹកជំនន់ទៅក្នុងកម្មវិធីសិក្សា និងកម្មវិធីផ្សេងៗរបស់សហគមន៍ ។

លំហូរនៃការបញ្ជូន និង ការទទួលពតិមាន




## អត្ថប្រយោជន៍គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍មានអត្ថប្រយោជន៍



*បង្គោលម៉ែត្រស្ទង់ទឹកដាក់នៅតាមផ្ទះរបស់អ្នកភូមិគឺជាឧបករណ៏ដ៏មានប្រសិទ្ធិភាពក្នុងការផ្តល់ពត៌មានកំពស់ទឹកជំនន់ទៅកាន់ប្រជាជន។ មិនមែនប្រជាជនទាំងអស់ទេ ដែលមានលទ្ធភាពទទួលពត៌មានពីក្តារពត៌មានទឹកជំនន់ ឬក៏បង្គោលម៉ែត្រស្ទង់ទឹក ដែលដាក់នៅក្រៅភូមិរបស់គេ។*

ជាច្រើន។ ពិសេសបានធ្វើអោយសហគមន៏ដែលងាយរងគ្រោះអាចទទួលពត៌មានជាមុនពីគ្រោះទឹកជំនន់បានទាន់ពេលច្បាស់លាស់ និងទៀងទាត់ ឧទាហរណ៏ អ្នកភូមិនៅតាមជនបទនៅក្នុងខេត្តព្រៃវែង កាលពីមុនខ្វះខាតពត៌មានពីកំពស់ទឹកជំនន់។កាលពីមុនការព្យាករណ៏កំពស់ទឹកជំនន់ មានតែនៅតាមទីប្រជុំជនធំៗ និងនៅជិតស្ថានីយ៏តាមដងទន្លេមេគង្គតែប៉ុណ្ណោះ។ សហគមន៏តាមជនបទភាគច្រើនមិនអាចទទួលបានពត៌មានទឹកជំនន់ច្បាស់លាស់ ទៀងទាត់និង មិនមានសំលេងតាមរយៈការផ្សាយតាមទូរទស្សន៏និងការផ្សាយតាមវិទ្យុ ។

ពត៌មាននៅតាមបង្គោលស្ទង់ទឹកបានកត់ត្រាដាក់ក្នុងសៀវភៅនិងមានផ្សព្វផ្សាយលើក្តារខៀនពត៌មានជាប្រចាំ។ ប្រការនេះជាហេតុធ្វើអោយមានការជឿទុកចិត្តទៅលើប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់នេះថាជាពត៌មានដែលគួរឱ្យជឿទុកចិត្តបាន ហើយគ្រប់គ្រងដោយអាជ្ញាធរភូមិ។ ជាមួយគ្នានេះដែរពត៌មានទឹកជំនន់នេះ បានធ្វើការផ្សព្វផ្សាយតាមពិធីបុណ្យទាននានាក្នុងភូមិ និងក្នុងទីប្រជុំជននានា។ លោក ម៉េង មនោរម្យ ជាអនុប្រធានភូមិខ្សាច់ បានប្រាប់អោយដឹងថា " ទោះបីអ្នកភូមិមួយចំនួន មិនអាចអានពត៌មានទឹកជំនន់នៅលើក្តារពត៌មានដែលបានដាក់នៅតាមភូមិរបស់គេក្តី ក៏មានអ្នកភូមិប្រហែលជា ៨៥ ភាគរយអាចយល់ដឹងពីពត៌មានទឹកជំនន់នេះដែរ តាមរយៈការផ្សព្វផ្សាយជាប្រចាំតៗគ្នា " ។

ម្យ៉ាងទៀតវគ្គបណ្តុះបណ្តាលដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំនិងអ្នកភូមិបានជួយបង្កើនការនូវកិច្ចសហការលើការគ្រប់គ្រងគ្រោះទឹកជំនន់ គ្រប់ថ្នាក់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ ។ដូចគ្នានេះដែរ គំរោងនេះបានបង្កើនការចែករំលែកពត៌មានគ្នាទៅវិញទៅមកផងដែរ ។

គំរោងនេះក៏បានផ្តល់ឱកាសក្នុងការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និង អង្គភាពជាដៃគូដូចជា កាកបាទក្រហមកម្ពុជា (CRC) និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (NGOs) នានា ទៅលើការអនុវត្តបង្គោលម៉ែត្រស្ទង់ទឹក និងការថែរក្សា ។ តាមរយៈការប្រើប្រាស់ពត៌មានទឹកជំនន់នេះ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការរីកចំរើន ហើយសហគមន៏អាចបង្កើតផែនទីទឹកជំនន់ និងផែនទីប្រើប្រាស់ដីនៅក្នុងភូមិនៅក្នុងការងារកសិកម្មរបស់ពួកគេបាន និងទទួលប្រយោជន៏ពីទឹកជំនន់ទន្លេមេគង្គ។

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋាន សហគមន៏មានតួនាទីធ្វើអោយមានទំនាក់ទំនងរវាងអាជ្ញាធរភូមិ និងសហគមន៏ក្នុងកិច្ចប្រតិបត្តិការ និងការថែរក្សាបង្គោលម៉ែត្រស្ទង់ទឹក និងការកត់ត្រាកំពស់ទឹកតាមរយៈការធ្វើអោយពួកគេទទួលបានផលប្រយោជន៏ដ៏ច្រើននៅក្នុងអភិវឌ្ឍន៏សហគមន៏និងផ្តល់ឱកាសធ្វើអោយមាននិរន្តរភាព និងភាពជាម្ចាស់។

## និរន្តរភាពទៅអនាគត

គំរោងកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) មានគោលបំណងធានាអោយមានការប្រើប្រាស់ និងអោយមានការចូលរួមសហការជាមួយរចនាសម្ព័នដែលមានស្រាប់នៅតាមសហគមន៏សំរាប់ការជួយសង្គ្រោះនៅពេលទឹកជំនន់។ គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋានសហគមន៏ បានធ្វើអោយមានការចូលរួមពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាជាដើម។

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅតាមមូលដ្ឋានសហគមន៏ក៏បានផ្តួចផ្តើមក្នុងការដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ-សង្កាត់ (CDP) និង ផែនការវិនិយោគឃុំ-សង្កាត់ (CIP)។ ដូចគ្នានេះដែរការផ្តួចផ្តើមក្នុងការបញ្ចូលប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៏ ជាចំនែកសំខាន់ដែលអាចបង្កើតអោយមានភាពជាម្ចាស់ការលើគំរោងនេះ ជាពិសេសវាអាចធានាបាននូវនិរន្តរភាពយូរ

អង្វែង ។

## មេរៀនបទពិសោធន៍ដែលទទួលបានកន្លងមក និងឧបសគ្គដែលនឹងអាចជួបប្រទះនៅពេលខាងមុខ

មានបទពិសោធន៍ជាច្រើនដែលទទួលបានពីការអនុវត្តគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុន ដែលបានអនុវត្តក្រោមគំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់នេះ ដូចមានខាងក្រោម:

- ការធ្វើដំណើរដើម្បីកត់ត្រាកំពស់ទឹកពីបង្គោលម៉ែត្រមានការលំបាកដោយសារខ្វះមធ្យោបាយធ្វើដំណើរ ។ ការចុះកត់ត្រាកំពស់ទឹកនេះត្រូវធ្វើចំនួន២ដងរៀងរាល់ថ្ងៃដោយប្រើប្រាស់ទូកដើម្បីធ្វើដំណើរ ។ ជាទូទៅនៅតាមផ្ទះនិមួយៗមានតែកូនទូកតូចតែមួយ ។ ទូកមួយនេះគេប្រើប្រាស់ដើម្បីបំរើក្នុងការដោះស្រាយ ជីវភាពរបស់គេដូចជា នេសាទត្រី ដឹកជញ្ជូនក្មេងៗទៅសាលា និង សំរាប់ដឹកទំនិញ ឬ ធ្វើដំណើរទៅផ្សារជាដើម ។ ដូច្នេះគេ មិនអាចប្រើប្រាស់ទូករបស់គេដើម្បីបំរើការងារនេះបានទៀងទាត់នោះទេ ។




*ការខ្សៀនពត៌មានត្រូវបានដាក់អោយប្រើប្រាស់យ៉ាងគ្រប់គ្រាន់ ក្នុងការផ្តល់ពត៌មានសំខាន់ទៅដល់អ្នកភូមិនៅក្នុងតំបន់ទឹកជំនន់*

- មានការលំបាកក្នុងការប្រើប្រាស់ឧបករណ៍ទំនាក់ទំនងដែលបានផ្តល់ជូន ។ វិទ្យុទាក់ទងភាគច្រើនមិនអាចប្រើប្រាស់បានដោយសារថ្មមិនអាចប្រើបានយូរ ឬ សាកមិនចូលភ្លើង មិនមានអគ្គិសនីសំរាប់សាកថ្ម ។ ជាទូទៅមធ្យោបាយទំនាក់ទំនងនេះមិនអាចប្រើដើម្បីទំនាក់ទំនងគ្នាបាន ។
- ការកត់ត្រាពត៌មានទឹកជំនន់ពីបង្គោលម៉ែត្រ និងការកត់ត្រាចូល ក្នុងសៀវភៅកំនត់ត្រាមិនបានត្រឹមត្រូវ ។
- អ្នកភូមិមួយចំនួនបានប្រាប់ថាទីទួលសុវត្ថិភាពមានមិនគ្រប់គ្រាន់ហើយខ្វះខាតសំភារ:ផ្គត់ផ្គង់ដែលចាំបាច់សំរាប់ប្រើប្រាស់នៅ ពេលទឹកជំនន់កើតមានឡើង ។

### ឧបសគ្គនៃការអនុវត្តគំរោងនាពេលអនាគត :

- មេភូមិដែលបានចាត់តាំងដោយគណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំអោយធ្វើជាអ្នកទទួលខុសត្រូវក្នុងការអនុវត្ត ប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់ដូចជា ការកត់ត្រាកំពស់ទឹក ពីបង្គោលម៉ែត្រ និងផ្សព្វផ្សាយពត៌មានជាប្រចាំ ។ ដើម្បីធានានិរន្តរភាពយូរអង្វែង គំរោងនេះគួរធ្វើអោយមានការចូលរួមពីអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ក្នុងការគ្រប់គ្រង និងអនុវត្តប្រព័ន្ធនេះផងដែរ ។
- ដំណោះស្រាយក្នុងការធ្វើអោយមាននិរន្តរភាពយូរអង្វែងកំពុងមានការរីកចំរើន ។ ផែនការនានាកំពុងស្ថិតនៅក្នុងដំណើរការនៃការបញ្ជ្រាបការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដូចជាការបញ្ជ្រាបប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។ នេះគឺជាការដាក់នូវការទទួលខុសត្រូវលើ កម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងដៃប្រជាជនកម្ពុជាទាំងអស់ ។
- ដើម្បីគាំទ្រអោយមានការបញ្ជូន និង ទទួលពត៌មានអោយកាន់តែបានលឿន ទៀងទាត់ និង ទាន់ពេល កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់របស់គណ:កម្មការទន្លេមេគង្គកំពុងគិតគូរកលទ្ធភាពដើម្បីប្រើប្រាស់ប្រព័ន្ធដែលមានតំលៃថោក ដូចជា តាមការផ្ញើសារពត៌មាន ឬ សារតាមទូរស័ព្ទចល័ត ( ប្រព័ន្ធ SMS ) ។


### សេចក្តីថ្លែងអំណរគុណ

សហគមន៍មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា
លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា
លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា
លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា
អ្នកស្រី Xanthe Cobb, អ្នកនិពន្ធ
លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្ត្រ និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្ត្រនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមានប្រទេស កម្ពុជា ឡាវ ថៃឡង់ដ៏និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែមនៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោមៈ

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៏បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល ។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោមៈ

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅក៏រិតមូលដ្ឋាន ស្តីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៏, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួមទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតំរូវការចាំបាច់របស់ស្ត្រីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៊ុដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៍ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វ៉ិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វ៉ិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៏នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៏នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

adpc

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វ៉ិបសាយ: www.adpc.net


ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)